ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១៧.១៨ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣០-៤-១៩៩៦-	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៣ តែងតាំងឯកឧត្តម ម្យាស់ លាស់ ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី ២	៧៣៤
០១-៥-១៩៩៦-	ព្រះរាជក្រឹត្យ ប្រទានមេដាយមាសការពារជាតិ ជាកិច្ចបច្ឆាមរណៈជូនសពឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុន ស៊ីដារ៉េ	៧៣៥
០១-៥-១៩៩៦-	ព្រះរាជក្រឹត្យ តម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈថ្នាក់ ឧត្តមសេនីយ៍ឯក ជូនចំពោះសព លោកឧត្តមសេនីយ៍ទោ អ៊ុន ស៊ីដារ៉េ	៧៣៦
០៣-៥-១៩៩៦-	ព្រះរាជក្រឹត្យ ជស/រកត ០៥៩៦/១៤ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ ជាន់ ងួន ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សាផលជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២	៧៣៨
០៧-៥-១៩៩៦-	ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៧ តែងតាំងឯកឧត្តម ស ណ្ហូត ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី ២	៧៣៩

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

០៧-៥-១៩៩៦ -	អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៤០
០៧-៥-១៩៩៦ -	អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៤១
០៧-៥-១៩៩៦ -	អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៤២
០៧-៥-១៩៩៦ -	អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រី រាជការ	៧៤៣

០៧-៥-១៩៩៦ – អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៥

០៨-៥-១៩៩៦ – អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ និង ទ្រទ្រង់សមរភូមិមុខ ៧៤៦

០៨-៥-១៩៩៦ – អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៧

០៩-៥-១៩៩៦ – អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រី រាជការ ៧៤៩

២ - សេចក្តីសំរេច

០៦-៥-១៩៩៦ – សេចក្តីសំរេចលេខ ១៣ សសរ.បក ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេស ដើម្បីសិក្សានូវគំរោងប្រើប្រាស់ថវិកាបដិភាគសំរាប់ថាមពលអគ្គិសនី ប្រើដោយពន្លឺ ប្រើដោយពន្លឺព្រះអាទិត្យ ៧៥០

០៩-៥-១៩៩៦ – សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង បង្ក្រាបការធ្វើអាជីវកម្មបញ្ចាំង និងលក់កាសែត្រវីដេអូអាសអាភាស ក្នុងរាជធានីភ្នំពេញ ៧៥២

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៣-៤-១៩៩៦ – ប្រកាសលេខ ៣៣០ ផក.ប្រក អនុញ្ញាតអោយលោក ប៉ោ លឹមហេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចស្ល និងកិនដែក ៧៥៤

០៩-៥-១៩៩៦ – ប្រកាសលេខ ៣៣៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឈឹម ប៊ុណ្ណារី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទឹកម្ទេស

និងទីក្រុង សញ្ញា «ក្រពើមាស» ៧៥៥

០៩–៥–១៩៩៦ – ប្រកាសលេខ ៣៣៥ ផក.ប្រក អនុញ្ញាតអ្នកស្រី ហោ សូណា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មកាត់ដេរ សំលៀកបំពាក់ ៧៥៥

០៩–៥–១៩៩៦ – ប្រកាសលេខ ៣៣៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស៊ុន សាខន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិន ស្រូវ កំលាំង ៩០សេះ ៧៥៦

០៩–៥–១៩៩៦ – ប្រកាសលេខ ៣៣៧ ផក.ប្រក អនុញ្ញាតអោយលោក ឡាំ ឡេងសុង ជាម្ចាស់ឧស្សាហកម្មតូចកែច្នៃក្រដាស «ភ្នំពេញ»ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក ស៊ុម សាក់ វិញ ៧៥៦

១៣–៥–១៩៩៦ – ប្រកាសលេខ ៣៤២ ថព.ប្រក អនុញ្ញាតអោយលោក នៅ សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ៧៥៧

១៣–៥–១៩៩៦ – ប្រកាសលេខ ៣៤៣ ផក.ប្រក អនុញ្ញាតលោយលោក លី ឃុន ជនជាតិខ្មែរសញ្ជាតិកម្ពុជា បើកដំណើរការសហគ្រាសផលិតគ្រឿងសង្ហារឹម ៧៥៨

១៣–៥–១៩៩៦ – ប្រកាសលេខ ៣៤៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី សៀន គន្ធា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ ៧៥៩

១៣–៥–១៩៩៦ – ប្រកាសលេខ ៣៤៥ ផក.ប្រក អនុញ្ញាតអោយលោក មឹង សៀន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ៧៥៩

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៩–៥–១៩៩៦ – ប្រកាសលេខ ១១២/៩៦ ពម.ប្រក អនុញ្ញាតអោយអ្នកស្រី

ហូ ស៊ូហួយ ប្តូរការប្រើប្រាស់ប្រព័ន្ធទូរស័ព្ទខ្សែកាប ដោយប្រើប្រាស់លោកធាតុអាកាស អឹម អឹមឌីអេស ជំនួសវិញ ៧៦០

១០–៥–១៩៩៦ – ប្រកាសលេខ ១១៣/៩៦ ពម.ប្រក អនុញ្ញាតជូនលោក ប៉ែន បភស្សនា បើកអាជីវកម្មរោងពុម្ពឈ្មោះ «ភ្នំពេញ» ៧៦១

១០–៥–១៩៩៦ – ប្រកាសលេខ ១១៤/៩៦ ពម.ប្រក អនុញ្ញាតជូនអ្នកស្រី លី សុខា បើកអាជីវកម្មរោងពុម្ពឈ្មោះ «តូតូ» ៧៦៣

២ -ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា

សារាចរណែនាំ

០៦–៥–១៩៩៦ – សារាចរណែនាំលេខ [illegible] ស្តីពីការអនុវត្ត ការដាំដើមឈើ តាមគ្រឹះស្ថានសិក្សា ៧៦៤

៤ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

០៣–៥–១៩៩៦– ប្រកាសលេខ ០៥៥ បទ.ប្រក ស្តីពីថ្លៃប្រើប្រាស់សេវាទូរគមនាគន៍ ក្នុងប្រទេស និង អន្តរជាតិ ៧៦៧

០៧–៥–១៩៩៦ – ប្រកាសលេខ ០៥៦ បទ.ប្រក ស្តីពីការផ្លាស់ប្តូរតួនាទី ភារកិច្ចមន្ត្រីរាជការ ៧៧៥

០៧–៥–១៩៩៦ – ប្រកាសលេខ ០៥៧ បទ.ប្រក ស្តីពីការតែងតាំងបជិគ្គាហកៈ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ៧៧៦

០៧–៥–១៩៩៦ – ប្រកាសលេខ ០៥៨ បទ.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការ ៧៧៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ

បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម្បាស់ លាស់** ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ទទួលបន្ទុកកិច្ចការផ្ទៃក្នុង និងមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្ត ព្រះរាជ ក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់រាជរដ្ឋាភិបាល

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រទានមេដាយមាសការពារជាតិ ជាកិច្ចបច្ឆាមរណៈជូនសពឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ិន ស៊ីផាវ៉** ដែលបានបូជាជីវិត នៅក្នុងសមរភូមិ ដើម្បីបុព្វហេតុការពារមាតុភូមិនិងប្រជាពលរដ្ឋ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណើ របស់រាជរដ្ឋាភិបាលកម្ពុជា

ត្រាសបង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈ ជាកិច្ចបច្ចាមរណៈ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនចំពោះសព ÷ លោកឧត្តមសេនីយ៍ទោ **អ៊ុន ស៊ីដារ៉េ** អត្តលេខ ០០០០៤១ ជាមេបញ្ជាការយោធភូមិភាគទី៥ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់ឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឥស្សរជន ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ដូច ខាងក្រោម ÷

១–ឯកឧត្តម ឧត្តមសេនីយ៍ទោ **ផាន់ ខួន** ទទួលបន្ទុកកិច្ចការអាកាសចរយោធាមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

២–ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សាផល** ទទួលបន្ទុកកិច្ចការអាកាសចរស៊ីវិលបន្ថែមលើមុខងារបច្ចុប្បន្នមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្ត ព្រះរាជ ក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/០៥៩៦/០១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់ឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់ឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៩៦

សម្រេចបង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ស ឈូត** ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ទទួលបន្ទុកការងារធម្មការ និងសាសនា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៤ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់អភិបាលស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ប្រគេនចំពោះព្រះគ្រូ វិជ័យមុនី កែ អ៊ុន អនុគណស្រុក ស៊ីធរកណ្តាល ដែលមានព្រះទ័យជ្រះថ្លា បានខិតខំកសាងសំណង់សាធារណៈផ្សេងៗ សំរាប់ជាប្រយោជន៍ដល់ប្រជារាស្ត្រទូទៅ នៅក្នុងស្រុក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើ របស់អភិបាល ខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ចំពោះ លោក យូ រី ប្រធានក្រុមហ៊ុន យូរី សាកូ ដែលបានបរិច្ចាគថវិកា ចំនួន ៥២.០០០ ដុល្លារអាមេរិក សំរាប់សាងសង់សាលារៀន មន្ទីរពេទ្យ សង្ឃារីមសិក្សា និងផ្ដល់រថយន្ត ០១គ្រឿង សំរាប់ដឹកអ្នកជំងឺ ជាប្រយោជន៍ ដល់ប្រជារាស្ត្រ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេតកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្ថលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៦ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនឯកឧត្តម ជា ប៉េងឈាង អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ចំនួន ១០.០០០ ដុល្លារអាមេរិក កសាងបានអាគារសិក្សា ០១ខ្នង នៅវិទ្យាល័យ សម្តេចឪ សម្តេចម៉ែ ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិសាត់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងអភិបាលខេត្តពោធិសាត់ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៦
- យោងអនុក្រឹត្យ ស្ដីពីការតែងតាំងមន្ត្រីរាជការ លេខ ៩៨ អនក្រ.តត ចុះថ្ងៃទី ២៩ សីហា ឆ្នាំ ១៩៩៥
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : កែសំរួលអនុក្រឹត្យ លេខ ៩៨ អនក្រ.តត ចុះថ្ងៃទី ២៩ សីហា ឆ្នាំ១៩៩៥ ដោយបន្ថែមនូវខ្លឹមសារដូចតទៅ :

តែងតាំងក្រុមជំនួយការ របស់សម្ដេចនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារវិនិយោគ មានឋានៈ ស្មើ «ប្រធាននាយកដ្ឋាន » នូវមន្ត្រី ដូចមានរាយនាមខាងក្រោម :

-លោក **តាន់ សំប៊ុន**

-លោក **សយ សុខា**

-លោក **ឧុយ ឆៅ**

-លោក **សាម៉ឺឌី ស៊ីទឡ្ហនា**

-លោក **តាំង ជាំវ៉ាហុង**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈ រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈរដ្ឋមន្ត្រីក្រសួង ប្រធាន

ស្ថាប័នពាក់ព័ន្ធនិងអស់លោក ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនលោក **គង់ រិទ្ធីវង្ស** អគ្គនាយក ក្លឹបយុវជនអន្តរជាតិ ដែលបានឧបត្ថម្ភថ្នាំពេទ្យដល់មណ្ឌលសុខភាព ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល មានតម្លៃគិតជាទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្ថលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៧៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ និងទ្រទ្រង់សមរភូមិមុខ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ អនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងទ្រទ្រង់សមរភូមិមុខ
- តាមសំណើ របស់អភិបាលខេត្តកំពង់ចាម

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « សេរីវឌ្ឍ » ស្ថាបនាជាតិ និងទ្រទ្រង់សមរភូមិមុខ ជូនចំពោះអង្គភាពក្រុមហ៊ុន ចំការកៅស៊ូ ០៤ នៅខេត្តកំពង់ចាម ដែលបានបរិច្ចាគថវិកា ជួយឧបត្ថម្ភ ដល់កងទ័ពនៅសមរភូមិមុខ ដូចមានរាយនាមខាងក្រោមនេះ ÷

១–ក្រុមហ៊ុនចំការកៅស៊ូ ចំការអណ្តូង ទឹកប្រាក់ ៣.០០០ ដុល្លារ US
២–ក្រុមហ៊ុនចំការកៅស៊ូ បឹងកេត ទឹកប្រាក់ ៣.០០០ ដុល្លារ US
៣–ក្រុមហ៊ុនចំការកៅស៊ូ មេមត់ ទឹកប្រាក់ ៣.០០០ ដុល្លារ US
៤–ក្រុមហ៊ុនចំការកៅស៊ូ ជប់ ទឹកប្រាក់ ៥.០០០.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី១ **នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា **ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៤០ អនក្រ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់អភិបាល ខេត្តកំពង់ចាម

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងអាគារសិក្សា នៅក្នុងខេត្តកំពង់ចាម ដូចមានខាងក្រោមនេះ ÷

ក–ជូនមេដាយប្រាក់ ស្ថាបនាជាតិចំពោះអង្គភាពការិយាល័យរុក្ខាប្រមាញ់ ខេត្តកំពង់ចាម ដែលបានជួយកសាងទីចាត់ការ សាលាបឋមសិក្សាទឹកជា អស់ប្រាក់ ៥.០៥០ ដុល្លារ US

ខ–ជូនមេដាយសំរិទ្ធ ស្ថាបនាជាតិ ចំពោះលោក **ស៊ឹម វណ្ណា** ប្រធានក្រុមហ៊ុនចំការកៅស៊ូបឹង កេត ដែលបានជួយកសាងអាគារសិក្សាផ្លូវលំ និងឧបត្ថម្ភប្រជារាស្ត្រ អស់ទឹកប្រាក់ ៨.៣០០០.០០០ រៀល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

អនុក្រឹត្យ

លេខ ៤១ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រី រាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ក្រសួងពត៌មាន

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង :

១-លោក **ស៊ិន សុខ** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

២-លោក **សេង សារុន** ជាប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយនិងសោតទស្សន៍

៣-លោក **មួង សុវត្ថិ** ជាប្រធាននាយកដ្ឋានមណ្ឌលពត៌មាន

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័ន

ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * *

២ - សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៦

សេចក្ដីសំរេច លេខ ១៣ សសរ.បក

ស្ដីពី

ការបង្កើត គណៈកម្មការបច្ចេកទេស ដើម្បីសិក្សា

នូវគំរោងប្រើប្រាស់ថវិកាបដិភាគសំរាប់ថាមពល

អគ្គិសនី ប្រើដោយពន្លឺព្រះអាទិត្យ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមស្មារតី ប្រជុំអន្តរក្រសួង នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការបច្ចេកទេស ដើម្បីពិភាក្សានូវគំរោងប្រើប្រាស់ថវិកាបដិភាគសំរាប់ថាមពលអគ្គិសនី ប្រើដោយពន្លឺព្រះអាទិត្យ ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **នាយ ចន** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២–ឯកឧត្តម **អ៊ិត ប្រាំង**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	អនុប្រធាន
៣–ឯកឧត្តម **លឹម គានហោ**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ អគ្គនាយក ធារាសាស្ត្រ	អនុប្រធាន
៤–លោក ជំទាវ **ហូ ឈួន**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២	សមាជិកា
៥–លោក **ជ័យ សាទខ្ម**	ប្រធានក្រុមហ៊ុន សំភារៈកសិកម្ម	សមាជិក
៦–លោក **សាម ម៊ុនហេង**	ប្រធាននាយកដ្ឋាន ហិរញ្ញកិច្ច	សមាជិក
៧–លោក **សួន សុខី**	ជំនួយការសម្តេចនាយករដ្ឋមន្ត្រីទី២	សមាជិក
៨–លោក **ហ៊ាន ម៉ុនធៀង**	ប្រធានការិយាល័យផែនការគណនេយ្យ ក្រុមហ៊ុនសំភារៈកសិកម្ម	សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

–សិក្សានូវគំរោងនានា ដែលប្រើប្រាស់ ថាមពលអគ្គិសនី ប្រើដោយពន្លឺព្រះអាទិត្យ

–សហការ និងសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធ និងក្រុមហ៊ុន មុន្នីស៊ី ណាម៉ិច ([illegible] អោយក្រុមហ៊ុន IBC Solartechnik) នៅកម្ពុជា ដើម្បីជំរុញដោះស្រាយ [illegible]កិច្ចការអោយ បានសមស្រប និងទាន់ពេលវេលា

–[illegible] ប្រចាំ អំពីដំណើរការនៃការងារនេះជូន [illegible]

ប្រការ ៣ : [illegible] ជិក គណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : [illegible]ម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៥ : [illegible]រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និ[illegible]មពល ឯកឧត្តម លោកជំទាវ អស់លោក ដែលមានចែងក្នុងមាត្រា១ ត្រូវទទួ[illegible]ក

អនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន អោយបានល្អប្រសើរចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

សេចក្តីសំរេច

លេខ ១៤ សសរ

ស្តីពី

ការបង្កើត គណៈកម្មការអន្តរក្រសួង បង្ក្រាបការធ្វើអាជីវកម្មបញ្ចាំង និងលក់ការ៉ែសេ្សតវីដេអូអាសអាភាស ក្នុងរាជធានីភ្នំពេញ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ និងចាត់វិធានការ បង្ក្រាបរោង បញ្ចាំង វីដេអូអាសអាភាស និងការលក់កាស្សែត អាសអាភាសទាំងឡាយក្នុងរាជធានី ភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈឬតំណាង	ជាប្រធាន
២–តំណាងក្រសួងមហាផ្ទៃ	ជាអនុប្រធាន
៣–តំណាងក្រសួងការពារជាតិ	ជាសមាជិក
៤–តំណាងក្រសួងពត៌មាន	ជាសមាជិក
៥–តំណាងសាលាក្រុងភ្នំពេញ	ជាសមាជិក
៦–តំណាងតុលាការរាជធានីភ្នំពេញ	ជាសមាជិក
៧–តំណាងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ	ជាសមាជិក
៨–តំណាងលេខាធិការដ្ឋាន កិច្ចការនារី	ជាសមាជិក
៩–តំណាងនាយកដ្ឋានភាពយន្ត និងវីដេអូ	លេខាកត់ត្រា

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ÷

–តាមដានត្រួតពិនិត្យការអនុវត្តអនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការគ្រប់គ្រងត្រួតពិនិត្យភាពយន្តនិងវីដេអូ ។

–ចូលត្រួតពិនិត្យគ្រប់រោងអាជីវកម្ម បញ្ចាំងភាពយន្ត វីដេអូ ។

–ត្រួតពិនិត្យគ្រប់កន្លែងធ្វើអាជីវកម្ម ជួលលក់កាស្សែតវីដេអូ ។

–ធ្វើកំណត់ហេតុ រៀបចំសំណុំរឿង លិខិតបទល្មើសពាក់ព័ន្ធ និងរបាយការណ៍ ជូនទីស្តីការ គណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : សមាជិក គណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង ពត៌មាន សាលាក្រុង ភ្នំពេញ តុលាការរាជធានីភ្នំពេញ លេខាធិការដ្ឋានកិច្ចការនារី មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីភ្នំពេញ នាយកដ្ឋានភាពយន្ត-វីដេអូ ដូចមាន

ចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាសលេខ ៣៣០ ឧក.ប្រក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ង៉ោ គីមហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ២៦៦០៩២ ភព.ចុះថ្ងៃទី ២៣_៣_៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣២ អឺ១ហ្សិត ផ្លូវ លេខ១៦៦ ក្រុមទី ៤៤ សង្កាត់ អូរឫស្សីទី ១ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបើកដំណើរការ ឧស្សាហកម្មតួច ស្ល និងកិនដែក «ខេមស្ទីល-CAMSTEEL» នៅក្នុងទីតាំង ភូមិជើងឯក សង្កាត់ ជើងឯក ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ង៉ោ គីមហេង** ត្រូវរៀបចំឧស្សាហកម្មតួច ស្លនិងកិនដែករបស់ខ្លួន អោយស្រេចជាស្ថាពរក្នុងរយៈពេល ៦ ខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣៣៤ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឈឹម ម៉ុណ្ណារី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេខ ២០៣៧៥៣ ភ.ព ចុះថ្ងៃទី ១៥–៣–៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិ ៣ ឃុំ ព្រះពន្លា ស្រុក សិរី សោភ័ណ ខេត្ត បន្ទាយមានជ័យ បើកដំណើរការសិប្បកម្មផលិត ទឹកម្ទេស និង ទឹកត្រី សញ្ញា «ក្រពើមាស»នៅក្នុងទីតាំង ភូមិ ស្វាភិ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : អ្នកស្រី **ឈឹម ម៉ុណ្ណារី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកម្ទេសជូរអែមម៉ាដា សញ្ញា «ក្រពើមាស»និងទឹកត្រីបង្កង៥ និង ទឹកត្រីកំពត សញ្ញា «ក្រពើមាស» ស្របតាមគំរូ សញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៣៥ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ហោ សុវណ្ណា** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០២៤១៦ ភ.ព ចុះថ្ងៃទី ១៧–៣–១៩៨៦ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៣៧ អឺ០ ផ្លូវលេខ ១៦៣ សង្កាត់ទួលស្វាយព្រៃទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៣៦ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស៊ុន សាខុន** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៥៩៣៤ ភ.ព ចុះថ្ងៃទី ៣១–១២–១៩៨៤ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៣៦ ផ្លូវលេខ ៣៥២ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញបើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៩០ សេះ នៅក្នុងទីតាំង ភូមិ តាមូង ឃុំ កំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

ប្រការ ២ : អ្នកស្រី **ស៊ុន សាខុន** ត្រូវចាប់ផ្តើមដំណើការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៣៧ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាំ សេងឡុង** ជាម្ចាស់ឧស្សាហកម្មតូចកែច្នៃក្រដាស «ភ្នំពេជ្រ» ដែលមានទីតាំងនៅផ្ទះលេខ ២៦ ផ្លូវលេខ ៧៥ សង្កាត់ ស្រះចក ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ផ្ទេរភារកិច្ចគ្រប់គ្រង ជូនលោក **ស៊ុមសាក់ វីនរឿងស៊ុន** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក ស៊ុមសាក់ វីនរឿងស៊ុន ជនជាតិ ថៃ កាន់ លិខិតឆ្លងដែន (PASSPORT) លេខ S0៤00៩៤ ចុះថ្ងៃទី ០៥–៩–១៩៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥២៦ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែលើ ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ ជាម្ចាស់ឧស្សាហកម្មតូចកែច្នៃក្រដាស «ភ្នំពេជ្រ» ដែលមានទីតាំង ដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : លោក **ស៊ុមសាក់ រីនហ្វៀនស៊ីន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដូចបានកំណត់ក្នុងប្លង់ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈ បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយ គ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៤២ ថ.ព.ប្រ.ក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **នៅ សុខា** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១៥៧០០៧ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣១ អឺ០ ផ្លូវលេខ ១៤១ សង្កាត់អូរឬស្សីទី២ ខ័ណ្ឌ ៧ មករា បើកដំណើរ ការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿងដែល មានកំលាំងសរុប ៣០០ KVA នៅក្នុងតំបន់បន្ទប់ភ្លើង លេខ ប.ត.២០៧ ដែលស្ថិត នៅផ្លូវលេខ ១៣៤ សង្កាត់វាលវង់ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **នៅ សុខា** ត្រូវអនុវត្តន៍ថ្លៃលក់ថាមពលអគ្គិសនីក្នុង១ KWH តាមរូបមន្ត

$$\frac{(350\text{៛} + H) + 700\text{៛} + h)}{H+h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ២០៧ ក្នុងខែមុន ។

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

៣៥០៛.ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

៧០០៛ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃអនុវត្តហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ ភ្លើងប.ត ២០៧យកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់បញ្ញត្តិ ឬ

បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៤៣ ឧក.ប្រក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លី ឃុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៤៨៧៦៣ ក.ព ចុះថ្ងៃទី ៣១-៨-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៦ ផ្លូវលេខ ៥៣ សង្កាត់ ផ្សារថ្មីទី ៣ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកដំណើរការ សហគ្រាសផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំង ភូមិ កោះអរ សង្កាត់ និរោធ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផលព្រមទាំងត្រូវគោរពរាល់ច្បាប់ និង បទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៣ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ សាឡុងឈើកៅអី តុ ទូ កៅអី គ្រែ ទ្វារ បង្អួច គ្រោងទ្វារ បង្អួចឈើក្រឡឹង ចម្លាក់ និងបាឡែត ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ដែលសាមីសហគ្រាស ត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៤ : ម្ចាស់សហគ្រាសត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់សហគ្រាសផ្ញើជូនមក ក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលរាជធានីភ្នំពេញ ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់សហគ្រាសត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៤៤ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សឿន គន្ធា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៦៣៨៣ ក.ព ចុះថ្ងៃទី ១៥-៥-៨៥ អាស័យបច្ចុប្បន្នភូមិព្រែក

ក្រាញ់ ឃុំ ព្រែកអំបិល ស្រុក ស្អាង ខេត្ត កណ្ដាល បើកដំណើរការរោងម៉ាស៊ីន កិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **សៀវ គន្ធា** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម អាជីវកម្មលើទីតាំងដូច បាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៤៥ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **មឹង សៀវ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ១១៦៣៨២ ក.ព ចុះថ្ងៃទី ១៥-៩-៩៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រែកក្រាញ់ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្ត កណ្ដាល បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **មឹង សៀវ** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំង ដូច បានកំណត់ក្នុង ប្លង់ដោយធានានូវទិន្នផលអង្គលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

២.ឧស្ដីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១២/៩៦ ពម.ប.ស.ឧ.ប្រក

អនុញ្ញាតឱ្យអ្នកស្រី ហូ ស៊ីហ្វួយ ប្ដូរការប្រើប្រាស់ ទូរទស្សន៍ខ្សែកាប

រដ្ឋមន្ត្រីក្រសួងពត៌មាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- ពិនិត្យលើសំណើសុំប្ដូរការប្រើប្រាស់ប្រព័ន្ធទូរទស្សន៍ខ្សែកាប ដោយប្រើប្រាស់រលក ធាតុអាកាស អឹមអឹមឌីអេស ជំនួសវិញលេខ ០១–៩៦ ស៊ីស៊ីធីវី ចុះថ្ងៃទី ២៩–៤–៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ហូ ស៊ីហ្វួយ** ប្ដូរការប្រើប្រាស់ប្រព័ន្ធទូរទស្សន៍ ខ្សែកាប ដោយប្រើ ប្រាស់រលកធាតុអាកាស អឹមអឹមឌីអេស ជំនួសវិញ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍នេះ ត្រូវគោរពតាមកិច្ចសន្យា និង ច្បាប់បញ្ញត្តិបទបញ្ជា ឬ សេចក្ដីណែនាំខាងផ្នែកសោតទស្សន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីមិនគោរពតាមកិច្ចសន្យា សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយក ទូរទស្សន៍ជាតិកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និង សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មាន រាជធានីភ្នំពេញ និង អាជ្ញាធរដែល ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៣/៩៦ ពម.ប្រក

អនុញ្ញាតជូនលោក ប៉ែន បកស្សនា បើកអាជីវកម្ម

រោងពុម្ព ដែលមានឈ្មោះ " ភ្នំពេញ"

* * *

រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ នស.រកម ១០.៩៦.១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤.៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « ភ្នំពេញ » របស់ លោក ប៉ែន បកស្សនា ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ប៉ែន បកស្សនា** ទីលំនៅផ្ទះលេខ២៥ ផ្លូវលេខ៤១០ ក្រុម ទី៤ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ព ដែលមាន

ឈ្មោះ « ភ្នំពេញ » ទីតាំងស្ថិតនៅ ផ្ទះលេខ ១៤ អា ផ្លូវលេខ ៣៣៤ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្រប ទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៤/៩៦ ពម.ប្រក

អនុញ្ញាតជូនអ្នកស្រី លី សុខា បើកអាជីវកម្មរោងពុម្ពឈ្មោះ "គូ.គូ"

រដ្ឋមន្ត្រី ក្រសួងពត៌មាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ នស.រកម ១០.៩៦.១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន

- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មានលេខ ១២២៤.៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « តួតូ » របស់អ្នកស្រី លី សុខា ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាត ជូនអ្នកស្រី **លី សុខា** ស្ថិតនៅផ្ទះលេខ ១៧ អឺ០ ផ្លូវលេខ ៣១០ សង្កាត់ទួលស្វាយព្រៃ ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ « តួតូ » ទីតាំង ស្ថិតនៅលំនៅស្ថានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

សារាចរណែនាំ

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៦

សារាចរណែនាំលេខ ០២ អយក.សរណន

ស្តីពីការអនុវត្តការដាំដើមឈើតាមគ្រឹះស្ថានសិក្សា

* * *

អនុលោមតាមស្មារតី នៃសារលិខិតរបស់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ លេខ ២៤២ ខុទ្ទ ៩៥ ចុះថ្ងៃទី ១២ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការចាត់វិធានការដាំដើមឈើតាមគ្រឹះស្ថានសិក្សា និងលិខិត របស់ក្រសួងអប់រំ យុវជន និងកីឡា លេខ៥២៩ អយក.ចទម ចុះថ្ងៃទី ០៩ មីនា ១៩៩៥ ស្តីពីការបំផុស ចលនាដាំដើមឈើ តាមគ្រឹះស្ថានសិក្សា ។

ដើម្បីអោយក្រសួងអប់រំយុវជន និងកីឡា ក្តាប់បាននូវស្ថានភាព និងសមិទ្ធផល នៃការដាំកូនឈើយកម្លប់ ឬ កូនឈើហូបផ្លែផ្សេងៗ សំរាប់សិស្សជ្រកផង និងក្នុងន័យរួមចំណែកកែលំអបរិស្ថាន សាលារៀនផង ក្រសួងសូមធ្វើការណែនាំ ដូចតទៅ :

ក្នុងឆ្នាំសិក្សានីមួយៗ ចលនាដាំដើមឈើនៅតាមសាលារៀន (បឋមសិក្សា និងមធ្យមសិក្សា) ត្រូវកំណត់ជាពីរដំនាក់កាល : ដំនាក់កាលទី១ គឺឆមាសទី១ (ពីដើមខែ តុលា រហូតដល់ចុង ខែ កុម្ភៈ) ឯដំនាក់កាលទី២ គឺឆមាសទី២ (ពីដើមខែ មីនា រហូតដល់ចុងខែ មិថុនា) ។ នៅជំនាច់ ឆមាសនីមួយៗ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រុង ត្រូវបំពេញតារាងស្ថិតិដើមឈើ (គំរូជូនភ្ជាប់) និង ធ្វើរបាយការណ៍ដោយឡែកអោយបានពិស្តារអំពី :

- ចំនួនកូនឈើដែលបានដាំដុះ តាមប្រភេទនីមួយៗ
- ប្រភពកូនឈើដែលបានយកមកដាំ
- វិធានការ នៃការថែទាំ
- ការលំបាក និង ការងាយស្រួល

- ដំណោះស្រាយផ្សេងៗ
- សំណូមពរ

ក្នុងន័យនេះ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រុង ត្រូវណែនាំបន្ថែមអោយ គ្រប់សាលារៀនបង្កើនចលនាដាំដើមឈើនេះអោយកាន់តែផុសផុល ហើយអោយសាលារៀនរាយការណ៍អោយបានច្បាស់លាស់ អំពីសកម្មភាព និងលទ្ធផលដែលទទួលបានក្នុងជំនាក់កាលនីមួយៗ ។

មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ក្រុង ត្រូវផ្ញើរបាយការណ៍បូកសរុប ស្ដីពីការដាំដើមឈើ ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា) ដោយភ្ជាប់មកជាមួយ នូវតារាងស្ថិតិដើមឈើអោយបានមុនដំនាច់ខែ កុម្ភៈ សំរាប់ជំនាក់កាលទី១ និងមុនដំនាច់ខែ មិថុនា សំរាប់ជំនាក់កាលទី ២ ។

ក្រសួងអប់រំ យុវជន និង កីឡា សង្ឃឹមថា អស់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា គ្រប់ខេត្ត ក្រុង អនុវត្តខ្លឹមសារ នៃសារាចរនេះប្រកបដោយប្រសិទ្ធភាព ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

មន្ទីរអប់រំយុវជន និងកីឡា **តារាងស្ថិតិសរុបកូនឈើដាំដុះក្នុងសាលារៀនចំណេះទូទៅ**

ខេត្ត_ក្រុង .... **ក្នុងឆមាសទី .... (១៩៩ .... ១៩៩ ...)**

ឧទាហរណ៍ : * * * *

ល.រ	ឈ្មោះដើមឈើ	បឋមសិក្សា		អនុវិទ្យាល័យ		វិទ្យាល័យ		សរុប	ដាំថ្មី	ផ្សេ
		សរុប	ដាំថ្មី	សរុប	ដាំថ្មី	សរុប	ដាំថ្មី			
១	ដើមដូង	៩០០ដ	១០០ដ	៥០០ដ	៥០ដ	៣០០ដ	៣០ដ	១៧០០ដ	១៨០ដ	
២	ដើមទឹកដោះ	៨០០ដ	៥០ដ	៤៥០ដ	៤០ដ	២០០ដ	២៥ដ	១៤៥០ដ	១១៥ដ	
៣	ដើមស្វាយ	២០០ដ	៤០ដ	៣០០ដ	៥០ដ	១៥០ដ	៣០ដ	៦៥០ដ	១២០ដ	
សរុបដើមឈើហូបផ្លែ		១៩០០ដ	១៩០ដ	១២៥០ដ	១៤០ដ	៦៥០ដ	៨៥ដ	៣៨០០ដ	៤១៥ដ	
១	ដើមគគីរ	៥០០ដ	១០០ដ	៧០០ដ	២០០ដ	៣០០ដ	១០០ដ	១៥០០ដ	៤០០ដ	
២	ដើមប្រេងខ្យល់	១៥០០ដ	៣០០ដ	២០០ដ	៥០ដ	៥០០ដ	៤០០ដ	២២០០ដ	៧៥០ដ	
សរុបដើមឈើយកម្លប់		២០០០ដ	៤០០ដ	៩០០ដ	២៥០ដ	៨០០ដ	៥០០ដ	៣៧០០ដ	១១៥០ដ	

* កំណត់សំគាល់ : –បញ្ជាក់ដើមឈើហូបផ្លែមុន (ក្នុងតារាង)

–សរុប : កូនឈើដាំពីមុនមក + កូនឈើទើបដាំថ្មី

ឧ. សរុប : ដូង : ៩០០ដ ក្នុងនោះដាំថ្មីក្នុងឆមាស ១០០ដ។

បានឃើញ និងឯកភាព ធ្វើនៅថ្ងៃទី ....

ប្រធានមន្ទីរអប់រំយុវជន និង កីឡា អ្នករាយការណ៍

* * *

៤ - ទីស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៥៥ បទ

ស្ដីពីថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៤៩៦/២០ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ

សំរេច

ប្រការ ១ : កំណត់ថ្លៃប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ ដូចមានឧបសម្ព័ន្ធទី១ ដល់ ឧបសម្ព័ន្ធទី៦ ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

ប្រការ ២ : ប្រកាសលេខ ០៣៨ បទ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥និងបន្ថែមឧបសម្ព័ន្ធទី ៦ ស្តីពីការផាកពិន័យលេខ ២៧៤៨ បទ ចុះថ្ងៃទី ០៥-១០-៩៥ រួមទាំងប្រកាសទាំងឡាយណាដែលមាន ពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ទុកជានិរាករណ៍ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋាន ផែនការគណនេយ្យ និងហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និង នាយកដ្ឋានប្រៃសណីយ៍ត្រូវទទួល បន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

<u>ឧបសម្ព័ន្ធទី ១</u> : ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

សំគាល់ : - រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាស តម្លៃអាជ្ញាប័ណ្ណស្មើ នឹង ពាក់កណ្តាលនៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

- ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវបង់តែតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសំរាប់អាជ្ញាប័ណ្ណថ្មី ។

- អ្នកកោសលុប ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

- អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ

១– ថ្លៃផ្តល់វិញ្ញាបនប័ត្រ	$
– កាវីវិទ្យុ	១៥
– វិទ្យុអាម៉ាទ័រ ថ្នាក់ទី១	១៥
– វិទ្យុអាម៉ាទ័រ ថ្នាក់ទី២	១២
– វិទ្យុអាម៉ាទ័រ ថ្នាក់ទី៣	១០
២– វិទ្យុប្រភេទ HF	$
ក-/ វិទ្យុប្រភេទ HF ចល័ត	
– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ	៥
– ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើនាវា	១៥
– ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើដីគោក	១០
– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង	
ចំពោះអានុភាព X watt និងបន្ទារហ្វ្រេកង់ Y KHz	២០+១.៥ X +២ Y
ខ-/ វិទ្យុប្រភេទ HF អចល័ត	$
– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ	៥
– ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង	១០
– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង	
- ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz	២០+០.៨ X +២ Y
៣– វិទ្យុប្រភេទ VHF	$
ក-/ វិទ្យុប្រភេទ VHF ចល័ត	
– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ	៤
– ការពិនិត្យថបនភ័ណ្ឌមួយគ្រឿង ។ មុនពេលតំលើង :	
ចំពោះវិទ្យុទាក់ទងតូចៗ កាន់ជាប់ នឹង ដៃ (walkie talkic)	៥

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ Y KHz ១០+ ០.៦X +០.៤Y $

ខ-/ វិទ្យុប្រភេទ VHF អចល័ត

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៤

– ការពិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ Y KHz ១០+០.៤X+០.៤Y $

៤- វិទ្យុប្រភេទ UHF និង SHF

៤.១ - វិទ្យុចល័តតូចៗកាន់ជាប់ នឹង ដៃ (walkie Talkie)

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៤

– ការពិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង : ៥

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ Y KHz ១០+០.៧X+ ០.៤Y

៤.២ - វិទ្យុប្រភេទអចល័ត

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង

៤.២.១ ប្រេក្វង់ទាបជាង ១ GHz

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ Y KHz ២០+៣X +០.៨Y

៤.២.២ ប្រេក្វង់ពី ១ - ៣ GHz

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ YKHz ២០+៤X + ០.៧Y

៤.២.៣ ប្រេក្វង់ចន្លោះពី ៣ ៨ GHz

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ YKHz ២០+៥X + ០.៦Y

ចំពោះអានុភាព X watt និង បន្ទាប្រេក្វង់ YKHz ២០+ ៦X + ០.៥Y

៤.២.៤ ប្រេក្វង់ពី ៨ GHz ឡើងទៅ

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz ២០+៦X+ ០.៥ Y

៤.៣ វិទ្យុប្រភេទចល័ត

ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ៨

ចំពោះទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១០

៤.៣.១ ហ្វ្រេកង់ទាបជាង 1 GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០+ ៤ X + ១ Y

៤.៣.២ ហ្វ្រេកង់ពី ១.៣ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៥ X + ០.៩ Y

៤.៣.៣ ហ្វ្រេកង់ចន្លោះពី ៣.៨ GHz

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៦ X + ០.៨ Y

៤.៣.៤ ហ្វ្រេកង់ពី ៨ CHz ឡើងទៅ

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ២០ + ៧ X + ០.៧ Y

៥– វិទ្យុទាក់ទងអន្តរជាតិ (ក្នុងករណីមានការអនុញ្ញាតពិសេស) $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ១០

– ការពិនិត្យបចេកទេសមួយគ្រឿងៗ មុនពេលតំលើង ២០

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់មួយគ្រឿង ២០ + ០.៨ X + ២ Y

៦– វិទ្យុផ្សាយសំលេង $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនីមួយៗ ៣០

– ការពិនិត្យបចេកទេសមួយគ្រឿងៗ មុនពេលតំលើង ៥០

ក-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ HF AM :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + ០.០៥ X + ២០Y

ខ-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ VHF FM :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + ០.០៥ X + ២Y

៧– ទូរទស្សន៍ $

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៣០

– ការពិនិត្យបចេកទេស មុនពេលតំលើង ៥០

ក-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ VHF :

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ YKHz : ១០០ + 0.0៥ X+ 0.0៥ Y

ខ-/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ UHF

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ១០០ + 0.0៥ X + 0.0៥ Y

៨– វិទ្យុអាម៉ាទ័រ

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០

– ការពិនិត្យឋបនភ័ណ្ឌ មុនពេលតំលើង ៥

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ២៥

៩–អ៊ិនម៉ាសាត

ក- អ៊ិនម៉ាសាតគ្រប់ប្រភេទ ប្រើប្រាស់លើដីគោក

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០០

– តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិនម៉ាសាតលើដី + ៣០%

– ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត១គ្រឿង ១.០០០

ខ– អ៊ិនម៉ាសាតប្រភេទ A . B និង C នៅលើនាវា

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ១០០

– តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ៣០០

ចំពោះអ៊ិនម៉ាសាតប្រភេទ A.B និង C នៅលើនាវា អតិថិជនអាចជ្រើសរើសយកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ អង្គការណាមួយក៏បាន ធ្វើជាអាជ្ញាធរទូទាត់ (Accounting Authority) សំរាប់ទូទាត់តម្លៃជាមួយស្ថានីយ៍អ៊ិនម៉ាសាតលើដី ។

ប្រសិនបើជ្រើសរើសយកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាអាជ្ញាធរសំរាប់ទូទាត់តម្លៃ :

– តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិនម៉ាសាតលើដី + ១០%

– ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត ១ គ្រឿង ៣.០០០

គ- ចំពោះអ៊ិនម៉ាសាត M ដែលចុះឈ្មោះនៅបរទេស

ហើយនាំចូលមកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា :

– ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៣០

– តម្លៃអាជ្ញាប័ណ្ណ :

តិចជាង ២០ ថ្ងៃ ២៥/ថ្ងៃ

ពី ២០- ២៥ ថ្ងៃ	៥០០
លើសពី ២៥ ថ្ងៃ	២០/ថ្ងៃ

ឧបសម្ព័ន្ធទី ២ : ថ្លៃប្រើប្រាស់បរិបថទិន្នន័យអន្តរជាតិ

ថ្លៃខាងក្រោមនេះមិនរាប់បញ្ចូលថ្លៃនៃប្រព័ន្ធទិន្នន័យក្នុងប្រទេសឡើយ ។

១– បរិបថអក្សរលេខ (Digital circuits)

ល្បឿន	ថ្លៃក្នុង១ខែ	ថ្លៃស្ថាបនា
KBit/s	$	$
២.៤	១.៥០០	៨០០
៤.៨	២.៥០០	១.០០០
៩.៦	៣.៣០០	១.៣០០
១៩.២	៤.០០០	១.៦០០
៤៨ឬ៥៦ឬ៦៤	៦.២០០	២.០០០
១២៨	៩.៨០០	២.៤០០
១៩២	១៣.៥០០	២.៨០០
២៥៦	១៦.២០០	៣.០០០
៣៨៤	២២.២០០	៣.៥០០
៥១២	២៨.៤០០	៤.០០០
៧៦៨	៤០.០០០	៤.៥០០
១០២៤	៤៨.៧០០	៥.០០០
១៥៤៤	៥៩.០០០	៦.០០០
២០៤៨	៦៦.០០០	៦.៥០០

២– បរិបថអាណាឡូក (Analogue circuits)

ប្រទេស	ថ្លៃក្នុង១ខែ	ថ្លៃស្ថាបនា
	$	$
ឡាវ ថៃ និង វៀតណាម	៤.០០០	១.៦០០
ប្រទេសដទៃ	៥.០០០	១.៦០០

ឧបសម្ព័ន្ធទី៣ : ថ្លៃបញ្ជូនរូបភាពទៅអន្តរជាតិ

ថ្លៃត្រឹមពាក់កណ្តាលផ្លូវ (គឺពីប្រទេសកម្ពុជាទៅផ្កាយរណប)

១– ការបញ្ជូនតាមប្រព័ន្ធ អ៊ិនតែលសាត (Tntelsat)	$
១០–នាទីដំបូង	៦០០
រាល់មួយនាទីក្រោយ	៣០
១– ការបញ្ជូនតាមប្រព័ន្ធ អ៊ិនទើស្ពុតនិក (Tnterspulnik)	$
១០–នាទីដំបូង	៤៤០
រាល់មួយនាទីក្រោយ	១២

ឧបសម្ព័ន្ធទី៤ : ថ្លៃប្រើប្រាស់ទូរពុម្ព

	$
ការស្ថាបនាខ្សែ	៣៨០
ការជួលជាប្រចាំខែ	៨០
ថ្លៃប្រើប្រាស់ក្នុងប្រទេស	$ (ក្នុង ១នាទី)
	០.៣០
ថ្លៃប្រើប្រាស់ទៅអន្តរជាតិ	$ (ក្នុង ១ នាទី)
ប្រទេសលាវ ថៃ និង វៀតណាម	៣.៨០
ប្រទេសអាស៊ីដទៃ	៤.០០
ប្រទេសដទៃ	៤.៨០

ឧបសម្ព័ន្ធទី៥ : ថ្លៃសុំច្បាប់ប្រើបរិធានទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា (Type Approval)

	$
ទូរស័ព្ទធម្មតា	១.០០០
ទូរស័ព្ទចល័ត	៣.០០០
ផេចជិញ	១.០០០
ទូរសារ	៣.០០០
បមាណី (PABX)	៣.០០០
បរិក្ខារវិទ្យុ	២.០០០
ការសុំបង្កើតភ្នាក់ងារនាំបរិធានទូរគមនាគមន៍ចូលប្រទេសកម្ពុជា	[illegible]

ថ្ងៃប្រចាំឆ្នាំ ១.០០

ឧបសម្ព័ន្ធទី៦ : ការផាកពិន័យ

សំគាល់ : ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

៦.១ ការប្រើប្រាស់បរិក្ខារវិទ្យុមួយគ្រឿងទោះចល័តក្តី អចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណប្រាក់ពិន័យស្មើនឹងតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារវិទ្យុនោះគុណនឹង ៥ ។

៦.២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណ នឹង ៤ ។

៦.៣ ការផ្លាស់ប្តូរថបនក័ណ្ឌវិទ្យុ ឬ ទីតាំងថបនក័ណ្ឌវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹងតំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខានោះគុណនឹង៣។

៦.៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃ បរិក្ខារនោះគុណ នឹង ២ ។

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាស

លេខ០៥៦ មន.ប្រក

ស្តីពីការផ្លាស់ប្តូរតួនាទី ភារកិច្ច មន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទ សម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- យើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការសហលក្ខន្តិក មន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ក្រុមហ៊ុនអាំងដូស៊ែតស្តីពីការស្តារ និងពង្រីកអគិតបណ្តាញទូរគមនាគមន៍ អ៊ិនធើរ នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ខ្សែរយៈបណ្តោយស្រប ស្តីពីការរៀបចំរចនាសម្ព័ន្ធ មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ខេត្ត ក្រុង
- បានឃើញសំណូមពរ និងការឯកភាពរបស់អភិបាលខេត្ត ពោធិសាត់
- ពិនិត្យសមត្ថភាព មន្ត្រីរាជការ

សំរេច

ប្រការ ១ : លោក កែប ឈឿប បច្ចុប្បន្នជាបផិត្តាហាកៈរងទទួលក្តាប់រួមមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត ពោធិសាត់អោយមកជាបផិត្តាហាកៈរងវិញ ។

ប្រការ ២ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្ត ពោធិសាត់ និង សាមីខ្លួនត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៣ : ប្រកាសលេខ ១៣៨ បទ.ប្រក ចុះថ្ងៃទី ៣០–៩–៩៥ លេខរៀងទី១ ត្រូវបាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

សូ ឃុន

រាជធានីភ្នំពេញ , ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាស លេខ ០៥៧ បទ.ប្រក

ស្តីពីការតែងតាំងបដិភូហាក: មន្ទីរប្រៃសណីយ៍

និង ទូរគមនាគមន៍

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញប្រកាសលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំរចនាសម្ព័ន្ធ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខ្សែរយៈបណ្តោយគ្រប់ខេត្តក្រុង
- បានឃើញសំណូមពរ និងការឯកភាពរបស់អភិបាលខេត្ត ពោធិសាត់
- ពិនិត្យសមត្ថភាព មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក អ៊ូ នៃ ជាបដិភូហាក: នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិសាត់ ។

ប្រការ ២ : បដិភូហាក:មានភារកិច្ចគ្រប់គ្រងដឹកនាំ និង ទទួលខុសត្រូវលើការងារសេវាកម្មអាជីវកម្ម ប្រៃសណីយ៍និងទូរគមនាគមន៍ ទូទាំងខេត្ត-ស្រុក ជូសមុខអោយក្រសួង ។

ប្រការ ៣ : នាយកខុទ្ទកាល័យ , អធិការដ្ឋាន , នាកយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយក - ដ្ឋានប្រៃសណីយ៍ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

សុ ឃុន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ប្រកាស

លេខ ០៥៨ បទ.ប្រក

ស្តីពីការផ្ទេរ មន្ត្រីរាជការ

* * *

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទ សម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម ០១៩៦.២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះរវាងក្រសួងប្រៃសណីយ៍ និទូរគមនាគមន៍ រ៉ែង ក្រុមហ៊ុនអាំងដូសាតស្តីពីការស្តារ និង ពង្រីកអគីតបណ្តាញទូរគមនាគមន៍ អ៊ុនគរេក នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ០៨២ ប្រក.បទ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំរចនាសម្ព័ន្ធ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខ្សែរយៈបណ្តោយក្រុង ខេត្ត–ក្រុង
- បានឃើញសំណូមពរ និងការឯកភាពរបស់អភិបាលខេត្ត ពោធិ៍សាត់

– ពិនិត្យសមត្ថភាព មន្ត្រីរាជការ

សម្រេច

ប្រការ ១ : លោក អ៊ុំ ឆៃ បច្ចុប្បន្នជាបជិត្តាហាកៈមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត ពោធិសាត់អោយទៅបំរើការងារនៅក្រុមហ៊ុនខាំមីនតែល បន្ថែមលើមុខងារសព្វថ្ងៃ ចាប់ពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៦ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាម៉ីខ្លួនក្រសួង នឹងរក្សាទុកដដែលគ្រាន់តែទទួលប្រាក់ភារកិច្ចបន្ថែមលើការងារសព្វថ្ងៃ ។ រីឯការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ពីក្រុមហ៊ុន គឺអាស្រ័យនៅលើក្រុមហ៊ុនខាំមីនតែលជាអ្នកផ្តល់ ទៅតាមសមត្ថភាព ជំនាញបច្ចេកទេស និងលទ្ធភាពនៃការងារ ។

ប្រការ ៣ : ខុទ្ទកាល័យ , អធិការដ្ឋាន , នាយកដ្ឋានផែនការគណនេយ្យ -ហិរញ្ញកិច្ច , នាយកដ្ឋាន ទូរគមនាគមន៍ក្នុងប្រទេស , មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្ត ពោធិសាត់ និង សាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

សូ យុន

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៨១០ រៀល